# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ឆែម ហួន ភេទប្រុស អាយុ៦៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័ត

## ស្រុកកំណើតនៅភូមិសង្វើយ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប

## រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:៥៣:០៥

## ២០ទំព័រ

ដានីៈ ដំបូងចង់ស្គាល់ឈ្មោះលោកពូ ។ ឈ្មោះហែម.. ។

ហួនៈ ឆែម "ឆ" ។

ដានីៈ ឆែម ។

ហួនៈ ហួន ។

ដានីៈ ឆែម ហួន លោកពូ?

ហួនៈ បាទ!

ដានីៈ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ហួនៈ ខ្ញុំអាយុ៦៨ឆ្នាំ ។

ដានីៈ អាយុ៦៨ឆ្នាំ?

ហួនៈ ឆ្នាំថ្មី ។

ដានីៈ ហើយមីងគាត់ឈ្មោះអីដែរ?

ហួនៈ ហោ រ៉ន ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ហួនៈ គាត់អាយុ៥៧ ។

ដានីៈ ស្រុកកំណើតលោកពូនៅណាដែរ?

ហួនៈ សៀមរាប មួយនៅតាកែវ ។

ដានីៈ មីងគាត់នៅតាកែវ?

ហួនៈ បាទ!

ដានីៈ ស្រុកកំណើតនៅសៀមរាប នៅភូមិអីដែរ?

ហួនៈ នៅភូមិអូរសង្វើយ ស្រុកជីក្រែង ។

ដានីៈ ហ្នឹងឃុំអីគេ?

ហួនៈ ឃុំសង្កើយហ្នឹងហើយ ។

ដានីៈ ភូមិអូរ ឃុំសង្កើយ?

ហួនៈ បាទ! ភូមិអូរ ឃុំសង្កើយ ។

ដានីៈ ភូមិអូរ ឃុំសង្កើយ ស្រុកជីក្រែង?

ហួនៈ សៀមរាប ។

ដានីៈ ហើយសព្វថ្ងៃលោកពូនៅភូមិអីដែរ?

ហួនៈ ខ្ញុំនៅភូមិអូរស្វាយ ។

ដានីៈ ភូមិអូរស្វាយ?

ហួនៈ ឃុំអូរស្វាយ ។

ដានីៈ ស្រុកអីដែរ?

ហួនៈ ស្រុកត្រពាំងប្រាសាទ ។

ដានីៈ ខេត្ត?

ហួនៈ ខេត្តឧត្តរមានជ័យ ។

ដានីៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ហួនៈ ខ្ញុំមានកូនចៅ៥នាក់ ប្រុស១ ស្រី៤ ។

ដានីៈ កូនធំៗអស់ហើយ?

ហួនៈ បាទ! ធំៗហើយ ។

ដានីៈ រៀនចប់អស់នៅ?

ហួនៈ អត់បានរៀនទេ កូនចៅបានរៀនថ្នាក់ទាបៗ យើងអត់សាលារៀន ទើបតែឥឡូវកើតអនុវិទ្យាល័យ ពីមុនអត់មាន បានថ្នាក់ទី២-៣ បានច្រើនទី៥ ។

ដានីៈ គាត់ឈប់អស់ហើយ?

ហួនៈ ឈប់អស់ ឥឡូវកូនរៀបចំមានគ្រួសារអស់ហើយ ។

ដានីៈ មានគ្រួសារអស់ទាំងអស់?

ហួនៈ នៅមួយពាក់អាវក្រហម ។

ដានីៈ ហើយឪពុកលោកពូគាត់ឈ្មោះអីដែរ?

ហួនៈ ឪពុកឈ្មោះ ឆែម ហម ។ មិនដឹងជាស្អីនាមរបស់គាត់មុនដំបូង ហ្នឹងឪពុករបស់គាត់ ដីតាមិនដឹងស្អី ។

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

ហួនៈ យូរហើយខ្ញុំប៉ែតសិប ។

ដានីៈ ម្ដាយលោកពូ?

ហួនៈ ម្ដាយខ្ញុំស្លាប់តាំងពីឆ្នាំ៦២-៦៣ ។

ដានីៈ គាត់ឈ្មោះអីដែរ?

ហួនៈ ឈ្មោះបិ ។

ដានីៈ បងប្អូនប៉ុន្មាននាក់លោកពូ?

ហួនៈ បងប្អូនគាត់ច្រើនដែរ ។

ដានីៈ បងប្អូនលោកពូ?

ហួនៈ បងប្អូនខ្ញុំ៤នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហួនៈ ស្រី១ ប្រុស៣ ។

ដានីៈ លោកពូកូនទីប៉ុន្មាន?

ហួនៈ ខ្ញុំកូនទី២ ។

ដានីៈ កាលពីក្មេងៗលោកពូបានរៀនសូត្រដល់ណាដែរ?

ហួនៈ ខ្ញុំមិនដារៀនសូត្រអីជ្រៅជ្រះទេផ្នែកសាលារដ្ឋ ខ្ញុំបួសរៀន៥ឆ្នាំដែរ ។

ដានីៈ បួសបានប៉ុន្មានឆ្នាំ?

ហួនៈ ៥ បួសខាងសាសនាទេ ។

ដានីៈ បានដល់ភិកទេ?

ហួនៈ បាន ។

ដានីៈ បួសភិកនៅវត្តណាទៅ?

ហួនៈ ខ្ញុំនៅវត្តខ្សាច់យើងភូមិអូរ ។

ដានីៈ វត្តខ្សាច់ ភូមិអូរ ។ ហើយសឹកឆ្នាំណាទៅ?

ហួនៈ ខ្ញុំសឹកមកឆ្នាំ៧១ ។

ដានីៈ សឹកហើយធ្វើអីវិញទៅ?

ហួនៈ កាលសម័យនោះឆ្នាំ៧១វាមានសង្គ្រាមម្ដង ចូលធ្វើទ័ពនឹងគេទៅ ។

ដានីៈ ចូលធ្វើទ័ពខាងទ័ពរំដោះ?

ហួនៈ បាទ!

ដានី៖ ទ័ពនៅក្នុងអង្គភាពណាដែលលោកពូ?

ហួន៖ កាលនោះមុនដំបូងនៅក្នុងអង្គភាព៧១៩ ។

ដានី៖ អង្គភាពអីគេអាហ្នឹង? អង្គភាពវរៈ ឬក៏កងពល?

ហួន៖ ហ្នឹងដូចថាតំបន់ ។

ដានី៖ តំបន់អីគេកាលហ្នឹង?

ហួន៖ កាលហ្នឹងគេហៅតំបន់នេះ តំបន់នោះ តំបន់៣៥ ភូមិភាគ៣០៤ ។

ដានី៖ ៣៥ហ្នឹងតំបន់សៀមរាប?

ហួន៖ បាទ!

ដានី៖ ពូកាលហ្នឹងនៅក្នុងកងទ័ពតំបន់៣៥?

ហួន៖ បាទ! គ្រាន់តែលេខគេ៧១៩ ។

ដានី៖ ពីណាគេធ្វើប្រធាន?

ហួន៖ កាលនោះគេហៅវរៈ តាហោះៗ ។

ដានី៖ លឺឈ្មោះគាត់ តាហោះ ហ្នឹងគេចាប់គាត់?

ហួន៖ បាទ!

ដានី៖ លោកពូចូលទៅជាមួយគាត់ធ្វើអីទៅ?

ហួន៖ ខ្ញុំធ្វើយុទ្ធជនធម្មតា ។

ដានី៖ នៅជាមួយគាត់ដល់ពេលណា?

ហួន៖ នៅរហូតដល់ឆ្នាំ៧៦-៧៧ ។

ដានី៖ ឆ្នាំ៧២-៧៣-៧៤នៅណា?

ហួន៖ កាលនោះខ្ញុំត្រឡប់មកធ្វើស្រែជាសហករណ៍ ។

ដានី៖ ឆ្នាំណា?

ហួន៖ ឆ្នាំ៧៧ហ្នឹង និយាយរួមឆ្នាំ៧៥មក ។

ដានី៖ ឆ្នាំ៧៥ យើងបែកភ្នំពេញ រំដោះភ្នំពេញ លោកពូចូលធ្វើកងទ័ពនៅវរៈហ្នឹងកងអង្គភាព៧១៩ ហ្នឹងតាំងពី៧១មករហូតដល់ពេល?

ហួន៖ ៧១ដល់៧៥ ។

ដានី៖ នៅក្នុងវរៈរបស់តាហោះ ហ្នឹងរហូត?

ហួន៖ នៅក្នុងហ្នឹងរហូត ។

ដានី៖ នៅអង្គភាពហ្នឹងដែរ?

ហួនៈ នៅហ្នឹងដែរ ។

ដានីៈ ដល់ពេលរំដោះឆ្នាំ៧៥យ៉ាងម៉េចវិញ?

ហួនៈ ដល់ពេល៧៥កងទ័ពមកឲ្យយើងធ្វើស្រែ ។

ដានីៈ ឆ្នាំ៧៥កងទ័ពធ្វើស្រែនៅកន្លែងណាទៅ?

ហួនៈ នៅតំបន់កំពង់ធំ ។

ដានីៈ ដល់ពេលហ្នឹងប្រែឈ្មោះអង្គភាពអីដែលអត់?

ហួនៈ ដូចជាខ្ញុំមិនបានចាប់អារម្មណ៍ នៅដដែល ឬផ្លាស់ទៅជាប៉ុន្មានវិញ ។

ដានីៈ ដល់ពេលអីចឹងចូលទៅកងទ័ពរបស់ភូមិភាគ ឬកងទ័ពរបស់តំបន់?

ហួនៈ ដូចនៅដដែល ឬចូលភូមិភាគ ឬយ៉ាងម៉េច ខ្ញុំអត់សូវចាប់អារម្មណ៍ ។

ដានីៈ មានដែលលឺកងពល១៧៤អីដែលអត់?

ហួនៈ អត់ដែលដឹង ។

ដានីៈ ប៉ុន្តែមកធ្វើស្រែនៅកំពង់ធំ?

ហួនៈ បាទ! ធ្វើស្រែកំពង់ធំ ។

ដានីៈ ធ្វើបានប៉ុន្មានឆ្នាំទៅ?

ហួនៈ ធ្វើបានប៉ុន្មាន ពីឆ្នាំ៧៥នៅរហូត ចិតសិបប៉ុន្មានដែលកងទ័ពវៀតណាមចូលក៏រត់ចូលព្រៃ យើងបេះតែខ្លាចតៗគ្នា ។

ដានីៈ ធ្វើស្រែរហូតនៅកំពង់ធំហ្នឹងពី៧៥-៧៩?

ហួនៈ បាទ!

ដានីៈ អត់មានផ្លាស់ទៅណាទេ?

ហួនៈ អត់ផ្លាស់ទៅណា ។

ដានីៈ មានការបែកបាក់អីមួយកកោកទៀត?

ហួនៈ បាទ?

ដានីៈ ភូមិភាគ៣០៤នេះគេដូរឈ្មោះដាក់ភូមិភាគឧត្តរ ក្រោយមកដាក់ភូមិភាគកណ្តាល ។

ហួនៈ មិនសូវដឹងដែរ ។

ដានីៈ កាលហ្នឹងអ្នកតស៊ូដូចតាហោះ ដូចមេមួយចំនួនទៀត ។

ហួនៈ ខ្ញុំដឹងថាតាហោះ គេចាប់

ដានីៈ ដល់ពេលតាហោះ ចាប់ ពីណាមកជំនួស?

ហួនៈ តាមវរៈខាងណាទេ គេហៅតាអី មកពីនិរតី ។

ដានី៖ ហៅអី?

ហួន៖ ខ្ញុំភ្លេចឈ្មោះបាត់ហើយ រកនឹកមិនឃើញ ខ្ញុំមិនបានចាប់អារម្មណ៍ កងពលហ្នឹង ។

ដានី៖ ឈ្មោះ វ៉ាន់ ឈ្មោះឆាយ?

ហួន៖ ឈ្មោះវ៉ាន់ ហ្នឹងហើយ ។

ដានី៖ មកជិនួសគាត់ ។

ហួន៖ បាទ!

ដានី៖ ប៉ុន្តែលោកតានៅកំពង់ធំរហូត?

ហួន៖ បាទ! នៅរហូត ។

ដានី៖ គេអត់មានបញ្ជូនឲ្យទៅវ៉ៃនៅតាមព្រំដែន?

ហួន៖ កាលនោះគេមានបញ្ជូនមែន តែយើងមួយចំនួនយើងនៅ យើងដូចថាយើងពិការ ។

ដានី៖ លោកតាពិការតាំងពីពេលណា?

ហួន៖ ខ្ញុំ៧៥ មុន៧៥ មុនរំដោះភ្នំពេញ ។

ដានី៖ លោកតាបានទៅវ៉ៃភ្នំពេញអត់?

ហួន៖ ខ្ញុំវ៉ៃសៀមរាប ។

ដានី៖ ពេលពិការ ពិការនៅណា?

ហួន៖ ពិការនៅសៀមរាប ។

ដានី៖ ពិការកន្លែងណាខ្លះ?

ហួន៖ ដាច់ដៃតិចតួច ហើយត្រូវក្បាលខ្លះ យើងមិនអាចធ្វើអីបានតទៅទៀត ។

ដានី៖ អីចឹងនៅកំពង់ធំនៅកន្លែងធ្វើ នៅក្នុងមន្ទីររបស់កងពល ឬនៅក្នុងមន្ទីររបស់អង្គភាពពិការ?

ហួន៖ កាលនោះមិនចូលក្នុងអង្គភាពណា ដូចថាគេបញ្ជូនអ្នកល្អៗទៅ នៅអង្គភាពទ័ពខ្លះ គេហៅចូលស្អីខ្ញុំអត់ដឹង ចេះតែនៅហ្នឹងគេ គេឲ្យទៅនៅចេះតែនៅ គេមិនរករឿងហេតុអីយើងសុំគេនៅចេះតែនៅ ។

ដានី៖ ដល់ពេលឆ្នាំ៧៩យួនចូលយ៉ាងម៉េចទៀតទៅ?

ហួន៖ យើងចេះតែរត់តាមគេទៅ ។

ដានី៖ រត់យ៉ាងម៉េច? ម៉េចបានអត់រត់ទៅផ្ទះ?

ហួន៖ វាវែងឆ្ងាយពេក ពីកំពង់ធំទៅផ្ទះឆ្ងាយណាស់ ។

ដានី៖ កំពង់ធំ?

ហួន៖ ប៉ុន្មានរយ ហើយគេមានកងទ័ពកាត់ៗ ។

ដានីៈ កំពង់ធំមកសៀមរាបជិតតាំ ឆ្ងងផុតស្ទោងមកដល់កំពង់ក្តី?

ហួនៈ ឆ្លងលំបាកណាស់ យើងមិនសូវរៀងហើយខ្លាចផង គេស្ទាក់មុខ ស្ទាក់ក្រោយ មានកងទ័ពដេញ មានកងទ័ពចាំ យ៉ាប់ណាស់កាលហ្នឹង ។

ដានីៈ ហើយរត់យ៉ាងម៉េចកាលហ្នឹង?

ហួនៈ ចេះតែរត់តាមសហជីព សហករណ៍គេទៅលើ រត់ចូលព្រៃ ។

ដានីៈ រត់ចូលព្រៃម្តុំណា?

ហួនៈ ខាងជើងភ្នំដី ខ្ញុំមិនសូវស្គាល់ទេចេះតែទៅតាមទេ មិនសូវស្គាល់ក្រឡុកក្រលៀតទេ ។

ដានីៈ រត់ពីភ្នំដីមកនៅជាមួយពីណា?

ហួនៈ ឥឡូវចេះ ដល់រត់មកជួបកងទ័ពគេសុំគេនៅទៀត កងទ័ព៥០២ មានគេថាកងទ័ពជើងអាកាសខ្ញុំសុំគេនៅជាមួយគេ បែកពីអង្គភាពសុំគេនៅជាមួយទៅ ។

ដានីៈ កងទ័ព៥០២ខាងជើងអាកាស?

ហួនៈ ខោគេខៀវៗសុំគេនៅជាមួយ ក្រោយមកបានមានគេនាំមកឡើងលើភ្នំដងរែក ។

ដានីៈ នៅកងទ័ពជើងអាកាស៥០២ជាមួយតាម៉េត?

ហួនៈ តាម៉េតក៏មិនមែន ។

ដានីៈ តារ៉ៃ?

ហួនៈ កងទ័ពហ្នឹងដូចជាចំ គេហៅតាផាត ។ តាផាត ហ្នឹងមិនមែនចាស់ប៉ុន្មានទេ តាផាត វាងក្មេងដែរ មិនមែនតាផាត នេះទេ តាផាតនេះមួយខ្ញុំទើបមកនៅជាមួយ ។

ដានីៈ តាផាត?

ហួនៈ តាផាត មានប្រពន្ធឈ្មោះលី នៅនេះ ។

ដានីៈ នៅភូមិអូរស្វាយដែរ?

ហួនៈ អូរស្វាយ តែគាត់ទៅនៅលិចអស់ហើយ តាំងពីយើងសមាហរណកម្ម ទៅនៅប៉ៃលិនខ្ញុំមិនសូវដឹង ។

ដានីៈ លោកពូមកនៅជាមួយកងទ័ព៥០២យ៉ាងម៉េចទៀតទៅ?

ហួនៈ ខ្ញុំនៅក្នុងកងទ័ព៥០២មួយរយៈទៅ ដូចថាយើងស្រាវជ្រាវរកបងប្អូនដែលថាទៅពីស្រុកភូមិស្រាវជ្រាវចេះតែដឹងដំណឹងមក មកជួបអ្នកស្គាល់នៅកងទ័ព៨០១ហ្នឹងឯង ក្រោយមកបំបែកមកផ្សេងទៀត ។ ជួបបងប្អូនក៏ស្គាល់គេ ខ្សែស្រឡាយខាងម៉ែយាយខ្ញុំ គេមិនជិតស្និតទេមិនមែនបងប្អូនទេតែនៅភូមិជិតភូមិ សុំគេមកជាមួយគេ ។

ដានីៈ ចេញពី៥០២?

ហួនៈ ចេញពី៥០២ ។

ដានីៈ តាំងពីកន្លែងភ្នំដីមក?

ហួនៈ អត់ទេ ហ្នឹងឡើងភ្នំហើយ ជួបគេ ។

ដានីៈ ឡើងមកជួបគ្នានៅណា?

ហួនៈ តាមផ្លូវមកមុំពា ស្រុកលាវ ។

ដានីៈ មកមុំពា?

ហួនៈ បាទ!

ដានីៈ កាលហ្នឹង៥០២គាត់នៅខាងហ្នឹងដែរ?

ហួនៈ ៥០២មិនមែនជាដុំកំភួនទេ អាចដាច់ដោយឡែក ដូចថាមានការខ្វះរត់ពីលិច ពីកើត នៅសល់៨-១០នាក់ តាផាត និងតាមៀន ធ្លាប់នៅជាមួយគាត់មួយរយៈ ។

ដានីៈ កាលហ្នឹងលោកពូរៀបការហើយ?

ហួនៈ នៅទេ មិនទាន់រៀបការទេ ក្រោយមកទៀតបានជួបយកគ្នានៅ ។

ដានីៈ យកគ្នាពីអន្លង់?

ហួនៈ យកគ្នាឆ្នាំ៨០ តាមមើល ខ្ញុំដើរវាវែងឆ្ងាយណាស់ ។

ដានីៈ លោកពូមានប្រសាសន៍មុំញនៅ៥០២រហូត?

ហួនៈ មិនមែនទេ ៥០២ឡើងមកលើភ្នំនៅប្រហែលជាប៉ុន្មានទេ ជួបគ្នាសុំគេនៅយើងដាច់ដោយពី សហជីព ក៏ទំនាក់ទំនងគ្នាស្គាល់គ្នាកង៩៣ អីចឹងមកនៅ៥០២មួយរយៈទេ ហើយជួបឆ្នាំ៨០ ដើរមកជាមួយគ្នា ខ្ញុំអត់ចេះចាំរឿងរ៉ាវដែលខ្លួនឯងធ្វើ វាលំបាក វាបត់បែនច្រើនពេក ។

ដានីៈ ចេញពី៥០២មកនៅជាមួយខាង?

ហួនៈ ៨០១នេះវាបំបែកហើយ វាមិនមែនជា៨០១ចំទៀត បំបែកពី០៥មកនៅជាមួយកង តាយន នេះ វាកន្លងទៅ១០ឆ្នាំជាងហើយ ពេលដែលខ្ញុំបែកចេញ ។

ដានីៈ កងតាយន លេខប៉ុន្មាន?

ហួនៈ កងតាយន លេខប៉ុន្មានមែនទែនទេ តានោះបានស្គាល់ ៧០៩, ៨០១កងដើម ៨០១កង ០៥ ។ ៧០៩ ឬ៧១៩ ខ្ញុំភ្លេចហើយ មិនដឹងមែនមិនមែន ។

ដានីៈ ៧០៩តាយន, តាប្រ៉ូ តាធិន?

ហួនៈ ហ្នឹងឯង ។

ដានីៈ តាប្រ៉ូ?

ហួនៈ តាប្រ៉ូ, តាធិន, តាយន ជាមួយគ្នា ។

ដានី:	ហ្នឹងកងយ៉ាងម៉េច? ចុះកង៨០០?

ហួន:	កង៨០០ ពីមុន៨០០មែន តែបំបែក៨០១បង្កើតកងពលមួយទៀត នោះ៧០៩ឲ្យតាឃន អ្នកកាន់កាប់។

ដានី:	ចុះតាធិន គាត់ទៅណាវិញ?

ហួន:	តាធិន បំបែកពី៨០០ទៅនៅស្រះឈូកនោះ គាត់បែកគ្នាហើយ មិនមែននៅជាមួយគ្នាទេ នៅតែ តាប្រ៉ី ទេនៅនេះ បំបែកជាកងដែលខ្ញុំដឹង។

ដានី:	លោកពូដឹបូងនៅ៥០២?

ហួន:	៥០២មិនបានជារាប់ឆ្នាំទេ ប្រហែលជាមួយខែ។

ដានី:	បានចូលមក៨០១?

ហួន:	បាទ!

ដានី:	មក៨០១បានយូរទេ?

ហួន:	៨០១ ខ្ញុំនៅយូរដែរ តាំងពីចុះពីលើមក នៅជាមួយតាឃន គាត់បំបែកពី៨០១យូរប៉ុន្មានខ្ញុំអត់ដឹងទេ។

ដានី:	តែកាលហ្នឹងលោកពូទៅមុំពាដែរ?

ហួន:	មុំពាយើងឡើងមក គេប្រមូលនៅក្នុងខ្មែរក្រហម ភៀសខ្លួនមកមុំពា មកទាំងអស់គ្នា។

ដានី:	នៅមុំពាយូរអត់ទេ?

ហួន:	នៅមុំពា ប៉ុន្មានឆ្នាំទេមកនៅ៨០១ នៅមុំពា មកនៅប្រជាជន ចេញពី៥០២តែខ្ញុំមិនបានថានៅប្រជាជន នៅប្រជាជន។

ដានី:	កាលហ្នឹងការហើយនៅ?

ហួន:	ការឆ្នាំ៨០។

ដានី:	ការនៅមុំពា ឬការនៅណា?

ហួន:	មិននៅមុំពាទេ នៅនេះហើយ ច្រើនកន្លែងពេកភ្លេចកន្លែងអស់មិនចាំសោះ។

ដានី:	ចេញពីមុំពាមកវិញ?

ហួន:	បាទ! ចេញពីមុំពាបានមកអូរត្រាវ។

ដានី:	មកនៅអូរត្រាវវិញ?

ហួន:	មិនចំអូរត្រាវទេ គេហៅវាលបារាំង ដងទង់ ខ្ញុំមិនសូវស្គាល់ទេ។

ដានី:	វាលបារាំង, ដងទង់, ចងក អីហ្នឹង?

ហួន:	បាទ!

ដានី: ហ្នឹងការនៅហ្នឹង?

ហួន: ការនៅខាងកើតហ្នឹងតិចទៀត មិនដឹងភូមិអីខ្ញុំមិនស្គាល់ទេ ។

ដានី: ដល់ពេលការហើយលោកពូនៅជាមួយកងតាយន?

ហួន: បាទ! កងតាយន ។

ដានី: មានចុះទៅធ្វើប្រតិបត្តិការខាងក្នុងអីអត់ទេ?

ហួន: ខ្ញុំនិយាយរួមមកនៅជាមួយគាត់មិនដែលបានទៅទេ ខ្ញុំគេឲ្យធ្វើគ្រូបង្រៀន បង្ហាត់កូនចៅ កូនក្មេងដែលកូនចៅខ្មែរក្រហម ។

ដានី: លោកពូធ្វើគ្រូបង្រៀនវិញ?

ហួន: បាទ! គាត់ឲ្យធ្វើគ្រូបង្រៀនក្មេង ។

ដានី: មានសេសសល់សៀវភៅបង្រៀនទេ?

ហួន: បាត់អស់ហើយគ្មានសល់អីទេ ខ្ញុំក៏មិនបានយកចិត្តទុកដាក់ប៉ុន្មាន រត់យកតែអាយុមានការអី ម្តងម្កាល ពិបាកទុកដាក់ ។

ដានី: កាលហ្នឹងបង្រៀន គាត់ឲ្យបង្រៀនក្មេងៗ?

ហួន: បាទ! និយាយរួមមិនដែលបានទៅមុខព្រោះយើង ។

ដានី: បង្រៀនពីអីខ្លះទៅ?

ហួន: អក្សរសាស្ត្រ គណិត បូក-ដកធម្មតា ។

ដានី: បង្រៀនអក្សរសាស្ត្រ បូក-ដកធម្មតា?

ហួន: គ្មានបង្រៀនប្រវត្តិសាស្ត្រ ឬក៏ស្អីទេ ។

ដានី: មានសៀវភៅបង្រៀនត្រឹមត្រូវ?

ហួន: សៀវភៅគេបើកឲ្យ មិនដឹងគេយកពីណាមក គេបង្កើតក៏មិនដឹង ខ្ញុំមិនដឹងដែរ ។

ដានី: បង្រៀនបានច្រើនឆ្នាំ?

ហួន: បង្រៀនរហូតខ្ញុំ ប៉ែតប៉ុន្មានទេដល់យើងធ្វើសមាហរណកម្មយូរដែរ ៨-១០ឆ្នាំដែរ ។

ដានី: កាលហ្នឹងបង្រៀន យ៉ាងម៉េចបង្រៀនមួយពេល?

ហួន: អត់ទេមួយថ្ងៃតែម្តង ព្រឹក-ល្ងាចៗរហូត ពីម៉ោង៧-១១ សំរាកពីរម៉ោង ម៉ោង២ បង្រៀនទៀត ។

ដានី: បង្រៀនដដែលៗឬបង្រៀនខុសគ្នា?

ហួន: វិធីបង្រៀន នោះជួនកាលក្មេងវាមិនសូវចេះចាំ យើងដាន់១-២ថ្ងៃ បើថាវាចេះចាំ មេរៀនទី១រហូតទីប៉ុន្មានដូចគ្នា ។

ដានី៖ ប៉ុន្តែបង្រៀនប៉ុន្មានថ្នាក់ទៅ? ពីព្រោះក្មេងៗ មានក្មេងតូច ក្មេងធំ?

ហួន៖ មានបង្រៀនម្ដុំផ្លូវចេញមកម៉ិញវាសាលាច្រើនដែរ គ្រូ៨-១០នាក់បង្រៀនថ្នាក់ទី១, ២, ៣ និងទី៤ អត់មានទៅលើទៀតទេ មានត្រឹមថ្នាក់ទី៤ ។ ក្មេង ហើយគ្រូក៏ក្រខាងចំណេះដឹងដែរយើងបានត្រឹមទី៤ ។

ដានី៖ តាស៊ី គាត់បង្រៀនដែលអត់?

ហួន៖ តាស៊ី គាត់ដូចអត់ទេ គាត់នៅក្រោយ គាត់នៅមន្ទីរតាយន ដែរ ។

ដានី៖ គាត់នៅមន្ទីរតាយន ដែរតែគាត់អត់បង្រៀនទេ?

ហួន៖ អត់បានបង្រៀនទេ គាត់ក្ដោបក្ដាប់ខាងអ្នកមកពីក្រោយ ។

ដានី៖ គាត់អត់បង្រៀនកូនសិស្សទេ?

ហួន៖ បាទ!

ដានី៖ ពូស្គាល់តាស៊ី តាំងពីអង្កាល់?

ហួន៖ តាស៊ី ទើបមកជួបគ្នានៅកន្លែងនេះឯង កន្លែងនៅជាមួយតាយន ។

ដានី៖ ពូមានប្រសាសន៍ថានៅជាមួយតាយន ទើបតែចុះមកបង្រៀននៅនេះទេ?

ហួន៖ បង្រៀននៅណាទេ បង្រៀននៅចងកបាន២ឆ្នាំ បានចុះមកហ្នឹង ។

ដានី៖ ពីមុនហ្នឹងធ្វើអី? មុនបង្រៀន?

ហួន៖ អត់ដែលបានធ្វើអីទេ ។

ដានី៖ អត់ដែលចុះទៅខាងក្នុង?

ហួន៖ អត់ទេ និយាយរួមតាំងពីនៅជាមួយគាត់ និយាយរួមតាំងពីរត់ចេញពីស្រុកខ្មែរមកចូលស្រុកគេ មិនដែលទៅមុខសោះ និយាយរួមតាំងពីឆ្នាំ៧៩រំដោះហើយមិនដែលបានទៅណា ។

ដានី៖ ពេលយើងបង្រៀនកូនសិស្សដល់ដាច់ឆ្នាំឲ្យឡើងថ្នាក់ដែលអត់ទេ?

ហួន៖ ឡើងថ្នាក់ធម្មតាតែមិនបានធ្វើការប្រឡងយកពិន្ទុអីប៉ុន្មានទេ គ្រាន់តែមើលសមត្ថភាពវាអានបាន បូកកើត យើងឡើងទៅ តែអត់មានខាងប្រវត្តិសាស្ត្រ មានតែលេខ និងអក្សរខ្មែរ ។ លេខដក លេខបូក ចែកធម្មតា តែ២មុខវិជ្ជាអត់មាន៣-៤ដូចយើងទេ សិក្សាសង្គមណាណីអត់ដឹងទេ ។

ដានី៖ រៀនហ្នឹងរហូតដល់ពេលណាបានផ្លាស់ប្ដូរ?

ហួន៖ ផ្លាស់ប្ដូរគ្រូ?

ដានី៖ បានន័យថាយើងបង្រៀនតែ២មុខ លេខបូក ហើយនិងអក្សរសាស្ត្រ ដល់ពេលណាបានចាប់ផ្ដើមរៀនត្រឹមត្រូវមានកម្មវិធី?

ហួនៈ មានកម្មវិធីសមាហរណកម្មហើយ ។

ដានីៈ អីចឹងកាលមុនហ្នឹងអត់បានរៀនអីត្រឹមត្រូវ ។

ហួនៈ អត់មានកម្មវិធីត្រឹមត្រូវ យើងសំដៅយកតែ២មុខវិជ្ជា ។

ដានីៈ រៀនចប់ត្រឹមថ្នាក់ទីប៉ុន្មានទៅ?

ហួនៈ រៀនថ្នាក់ទី៤ដាក់សៀវភៅគេ ខ្ញុំបង្រៀនបានប៉ុណ្ណឹង ។

ដានីៈ ប្រុកនេះហៅប្រុកអីគេ ពីរង្វង់មូល?

ហួនៈ ខ្ញុំដឹងថាកន្លែងនេះក្បាលអូរស្វាយ តែប៉ុណ្ណឹង ។

ដានីៈ តែឡើងទៅលើនោះស្អីគេទៅ?

ហួនៈ ឡើងទៅលើខ្ញុំអត់ដឹង មិនដឹងគេដាក់វាលស្អីៗ ខ្ញុំអត់ដែលទៅសោះ ។

ដានីៈ ចុះក្បាលទន្សោងនៅណា?

ហួនៈ ក្បាលទន្សោងនៅលិចនោះធ្លាប់ដឹង នៅអន្លង់វែង ធ្លាប់ដឹងហ្នឹងធ្លាប់មែន ។

ដានីៈ ក្បាលទន្សោងនោះមិនមែននៅលើនេះទេ?

ហួនៈ ទៅឆ្ងាយណាស់ប្រហែល២០គីឡូទៀត ។

ដានីៈ ប៉ុន្មានគីឡូ?

ហួនៈ ២០ជាងដឹង និយាយរួមផ្លូវស្រះឈូក ផ្លូវឡើងភ្នំ ។

ដានីៈ ស្រះឈូក-ដាំ?

ហួនៈ បាទ! ស្រះឈូក ក្បាលទន្សោងឡើងទៅជាប់គ្នា ។

ដានីៈ ចាំមើលស្រះឈូក មកពើយតារូន ។

ហួនៈ ពើយតារូនខ្ញុំអត់ដែលស្គាល់ទេ ។

ដានីៈ ក្រោយមក២០-៣០គីឡូទៀតនោះបានដល់ក្បាលទន្សោង?

ហួនៈ អត់ទេ ក្បាលទន្សោងខ្ញុំធ្លាប់ដឹងឡើងពីស្រះឈូកទៅដល់ដាំ ហើយដាំមកនេះគិតក្បាលទន្សោង ។

ដានីៈ ខ្ញុំធ្លាប់ទៅដល់កន្លែងប៉ុស្តិ៍វិទ្យុតាម៉ុក ។

ហួនៈ អត់ដែលស្គាល់ទេប៉ុស្តិ៍វិទ្យុ ។

ដានីៈ ដល់ខ្ញុំសួរគេហ្នឹងទាល់តែធ្វើដំណើរម៉ូតូ២០គីឡូទៀតបានដល់ ។

ហួនៈ ស្រេចហើយរឿងដែនទី ។

ដានីៈ នេះដាំ?

ហួនៈ ម្តុំត្រង់នេះ បើថាហ្នឹងដាំ ។ ឆ្ងាយខ្ញុំដើរពីដាំដល់ក្បាលទន្សោង ។

ដានី:	ធ្លាប់ដើរទៅ?

ហួន:	កាលនៅចុះមកពីលើនៅអន្លង់វែង ឲ្យយកអង្ករក្បាលទន្សោង ។

ដានី:	កន្លែងផ្ទះតា ៗ នៅ?

ហួន:	ផ្ទះតា ៗ នៅអត់ដែលដឹងទេ មិនដឹងត្រង់ណា និយាយរួមមិនដែលឃើញផ្ទះ មិនដែលស្គាល់មុខតែម្ដង ។ ថាយើងប្រជាជន ឬកងទ័ពដែលតែយើងតូចតាចយើងអត់ដឹង ។

ដានី:	កន្លែងទល់មុខប្រោក?

ហួន:	សព្វថ្ងៃគេហៅពើយតារួន, ទឹកខៀវ ខ្ញុំគ្រាន់តែលឺគេហៅ និយាយរួមមិនដែលស្គាល់តែម្ដងអត់ដឹងទេ ហើយវាលត្រង់ណា គេហៅវាលថ្មដារ វាលដងទង់ ខ្ញុំគ្រាន់តែលឺគេថាមិនដែលទៅ និយាយរួមចាប់មកពីឆ្នាំប៉ុន្មានមកដល់ថ្ងៃនេះមិនដែលឡើងទេភ្នំ អត់ដែលសោះ ។

ដានី:	អីចឹងឲ្យទីតាំងច្បាស់អី ពូអត់ច្បាស់?

ហួន:	អត់ច្បាស់ទេ បើក្បាលទន្សោងខ្ញុំដឹងថា ខ្ញុំដើរពីជាំត្រង់ផ្សារឡើងទៅពីយើងដល់កន្លែងកាច់មានកន្លែងគេហៅកន្លែងពួកតាម៉ុក នៅគេហៅវាលអីទេមានផ្ទះ ។

ដានី:	អូរក្រញ៉ូង?

ហួន:	សព្វថ្ងៃមិនដែលស្គាល់អូរក្រញ៉ូងទៀត លឺតែយាយ ៗ ថាទៅវត្តអូរក្រញ៉ូង ខ្ញុំមិនដឹងត្រង់ណាក្បាលទន្សោងបើខ្ញុំដើរពីកន្លែងហ្នឹងទៅមិនឆ្ងាយប៉ុន្មានទេ ។

ដានី:	ដើរប្រហែលប៉ុន្មានម៉ោង?

ហួន:	ប្រហែល ១ ម៉ោង ដូចជិតដែរក្បាលទន្សោង១ ធ្លាប់ដើរទៅយកអង្ករ ចុះមកនៅខ្ញុំនៅក្រោមកាលចុះពីលើមកខ្ញុំនៅត្រពាំងប្រិយ៍ ។ ក្រៅពីនោះមកខ្ញុំមិនដែលស្គាល់ទេ មិនដែលបានឡើងលឺគេថាវាលត្រង់ណា ៗ ខ្ញុំលឺតាមគេ ។

ដានី:	ពេលតាម៉ុក តាប៉ុល ពត ឈ្លោះគ្នា ដល់ក្រោយមកតាម៉ុក, តាខៀវ សំផន រត់ទៅរូងភ្នំណាមួយ ក្រែងនៅកន្លែងអូរស្វាយ?

ហួន:	ខ្ញុំអត់ដឹងទេរឿងហ្នឹង អត់ដឹងទេ លឺតែឈ្លោះគ្នា តាប៉ុល ពត ទៅណា ៗ និយាយរួមមិនដែលឃើញតែម្ដង ។

ដានី:	តែគេថានៅកន្លែងអូរស្វាយមានភ្នំមួយឡើងទៅ ក្រោយមកគេតាមគាត់ទាន់នៅកន្លែងហ្នឹង?

ហួន:	និយាយរួមបើថាអីចឹងខ្ញុំអត់ដឹងកន្លែងគេ និយាយរួមអត់ដឹងតែម្ដង សួរបងប្អូនបើថាខ្ញុំកុតខ្ញុំកុហក និយាយរួមមិនដែលបានឡើង មិនដែលដឹង ។ ដឹងថាសភាពការណ៍គេឈ្លោះគ្នា តែមិនដឹងថាមានភ្នំប៉ុន្មានគេលាក់ខ្លួន គេទៅទាន់កន្លែងណាខ្ញុំអត់ដឹង និយាយរួមខ្ញុំតូចតាចគេមិន

ឲ្យយើងដឹង ដឹងតែគេថាឈ្លោះគ្នា ដឹងមែនគេឈ្លោះគ្នា គេដឹងចាប់ គេចង គេដេញតាមត្រង់ណា យើងអត់ដឹងទេ ។

ដានី: គេឈ្លោះហ្នឹងគ្នាពូមានដឹងមូលហេតុអីបានគេឈ្លោះគ្នា?

ហួន: និយាយរួមដូចខ្ញុំបានជំរាប ខ្ញុំយុទ្ធជន ខ្ញុំអ្នកពិការគេមិនសូវឲ្យយើងដឹងទេអ៊ីៗ គេម៉េចក៏ម៉ាទៅឲ្យតែបានសុខនិយាយរួម កុំចង់ដឹងចង់លឺ ខ្ញុំមិនចង់ដឹងចង់លឺសោះរឿងចឹងៗ អត់ចង់ដឹងចង់លឺ បើគេថាឲ្យរត់ៗនឹងគេទៅ ។

ដានី: លោកពូចុះមកពីលើភ្នំមកនៅនេះតែម្តង ឬនៅណា?

ហួន: អត់ទេខ្ញុំចុះមក ដូចខ្ញុំជំរាបជូនខ្ញុំនៅនោះទេ ជាមួយតាយន មកត្រពាំងប្រិយ៍គាត់បើកអន្តរទៅក្បាលទន្លេរាងមែនៗ ដើរមកពីត្រពាំងប្រិយ៍ទៅនៅទំនប់ដាច់ មានសភាពការណ៍ទាហានដេញមកនៅកន្លែងនេះរហូតតាំងពីឆ្នាំ៩៤-៩៥ ។

ដានី: ទៅនៅកន្លែងត្រពាំងប្រិយ៍បានយូរដែរ?

ហួន: នៅបាន១ឆ្នាំ ។

ដានី: ហើយផ្លាស់ទៅណាវិញ?

ហួន: ទៅកើត ទៅទំនប់ដាច់ ទៅនៅទំនប់ដាច់ កាលហ្នឹងទាហានរដ្ឋាភិបាលដេញមកយើងមកនេះវិញទៅ ដឹងតែសភាពការណ៍មិនស្រួលគេជម្លៀសយើងហើយ យើងខាងក្រោយ ។

ដានី: អីចឹងទៅនៅខាងត្រពាំងប្រិយ៍បានមួយឆ្នាំ ពេលចុះមកឆ្នាំ៩០ហ្នឹង?

ហួន: ៩២-៩៣កាលហ្នឹងយើងចុះមកពីលើភ្នំ ។

ដានី: ចុះហើយម៉េចបានទៅទំនប់ដាច់?

ហួន: សភាពការណ៍វាប្រែប្រួល វាដូចថាគេបំបែកកងតាយន ហើយមួយសារនោះ បំបែកកងតាយន ពីតាធិន ឲ្យទៅកើតនៅជាមួយ០៥ ។ តែបង្កើតកងថ្មី ខ្ញុំមិនសូវដឹងទេ ទៅនៅណាខ្ញុំនាំបងប្អូនកូនក្មេងធ្វើសាលារៀនចេះតែបន្លាត់ទៅ ។

ដានី: ទៅនៅទំនប់ដាច់បន្លាត់នៅទំនប់ដាច់ដែរ?

ហួន: បាទ! ទៅទំនប់ដាច់ បន្លាត់ទំនប់ដាច់ ទៅត្រង់ណាបន្លាត់នោះឯង ។

ដានី: កាលហ្នឹងពីណាគ្រប់គ្រងនៅទំនប់ដាច់?

ហួន: កាលហ្នឹងតាយន ដដែល តែមានពីលើតាយន គឺ០៥នៅខាងលិច តែអត់ចូលគ្នាទេ ។

ដានី: ទៅនៅទំនប់ដាច់បានរយៈពេលប៉ុន្មាន?

ហួនៈ បែបមួយឆ្នាំដែលដឹង ខ្ញុំមិនសូវទូទាត់ចាំដែរ អាច១វស្សា ធ្វើផ្ទះសំបែងមិនទាន់រួចផង រត់លូនគេទៅទៀត វែងណាស់ វែងអន្ទាយណាស់រកវគ្គ រកឃ្លាមួយណាមុន ក្រោយមិនឃើញព្រោះវាយូរពេកខ្ជិលគិត ខ្ជិលគូររឿងលំបាក បើនិយាយទៅស្មុគ្រស្មាញ ឃើញតែលំបាក

ដានីៈ ដល់ពេលទាហានរដ្ឋាភិបាលដេញពីទំនប់ដាច់មកនៅ?

ហួនៈ មកនេះ ។

ដានីៈ មកនៅឆ្នាំណាហ្នឹង? ឆ្នាំកៅប៉ុន្មានលោកពូមានប្រសាសន៍មិញ ៩៤?

ហួនៈ ៩៤-៩៣ អេ៎ ៩៣មិនមែនទេ ៩៥ ខ្ញុំភ្លេចទៅវាអត់ចាំទេ ៩៤-៩៥ នៅមួយកន្លែងៗវាមិនបានយូរទេ តែមើលទៅដូចថានិយាយទៅវាអត់ស៊ីគ្នា ៩៣ចុះពីលើ ៩៤បេះមកៗ ៩៥មកនេះ ។ ទំនប់ដាច់កៅប៉ុន្មាន ធ្វើសមាហរណកម្មនេះពេលរំដោះ រួបរួម៩៨-៩៩ វាអត់បានយូរទេ បើមួយឆ្នាំៗដូចមិនមែន ។

ដានីៈ ពេលដែលមកនៅឆ្នាំ៩៨ហ្នឹង នៅនេះគេបោះឆ្នោតឆ្នាំណាទៅ?

ហួនៈ បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ?

ដានីៈ បាទៗ

ហួនៈ ដូច២០០០ដឹង ឬ៩៩ខ្ញុំភ្លេចទៅ ។

ដានីៈ ៩៨?

ហួនៈ ៩៨សមាហរណកម្ម ។

ដានីៈ មុនសមាហរណកម្មមានបោះឆ្នោត?

ហួនៈ បោះមុនដំបូងមិនដឹង៩៨, ៩៩ បោះម្តង ។

ដានីៈ បោះទៅមានរឿងអីកើតឡើង?

ហួនៈ ដូចអត់មានរឿងអីកើតឡើងខាងខ្ញុំ ។

ដានីៈ តែកាលហ្នឹង ពេលបោះឆ្នោតលើកដំបូងពួកតាម៉ុក នៅលើភ្នំ? គេមានបាញ់ហិបឆ្នោតដែលអត់?

ហួនៈ លឺតែគេថា អត់បាញ់កន្លែងនេះទេ ។

ដានីៈ បាញ់នៅណាទៅ?

ហួនៈ បាញ់នៅថ្នល់ក្រហម ។

ដានីៈ ថ្នល់ក្រហមនៅណាទៅ?

ហួនៈ ថ្នល់ក្រហម ថ្នល់កៅស៊ូយើងសព្វថ្ងៃ ។

ដានីៈ ហ្នឹងគេហៅថ្នល់ក្រហម?

ហួនៈ ពីមុនថ្នល់ក្រហម តាមនេះគ្មានថ្នល់ទេ មានតែផ្លូវដើរ ឃើញសែនហិបឆ្នោតតាមផ្លូវដើរ ហើយភ្លៀងប៉ិចប៉ិចបាច់ផង អត់មានដែលបាញ់ទេនេះ បើបាញ់ៗនោះឯង ។

ដានីៈ ម៉េចបានគេបាញ់?

ហួនៈ ខ្មែរក្រហមមិនត្រូវនឹងយើងណា៎ ។

ដានីៈ កាលហ្នឹងយើងចូលជាមួយរដ្ឋាភិបាលបានគេបាញ់?

ហួនៈ យើងចូលធ្វើសមាហរណកម្មចូលជាមួយរដ្ឋាភិបាល តែខ្មែរក្រហមកាលហ្នឹងនៅលើភ្នំខ្លះដឹងបានអីចឹង នៅខ្លះហើយបានបាញ់ ។

ដានីៈ ដល់ពេលចូលយើងសមាហរណកម្មចូលជាមួយរដ្ឋាភិបាលហើយយ៉ាងម៉េចទៅ កាលហ្នឹងពូនៅកន្លែងណា?

ហួនៈ ខ្ញុំនៅកន្លែងនេះដដែល ។

ដានីៈ អត់មានទៅណាតាំងពីឆ្នាំ៩៨?

ហួនៈ អត់ នៅតែហ្នឹង ។

ដានីៈ ធ្វើអីទៅដល់ពេលចូលសមាហរណកម្មហើយ?

ហួនៈ ចាប់ពីនោះមកខ្ញុំក៏ ខាងអភិបាលគាត់ដូចថាខ្ញុំជំនាញខាងគ្រូបង្រៀន គាត់ភ្ជាប់ខាងគ្រូ ឲ្យខ្ញុំទៅរៀនសូត្រនៅសៀមរាបប៉ុន្មានខែដែរ ហ្នឹងសមាហរណកម្មភ្លាម បានខ្វះប៉ុន្មានទេកាលហ្នឹង កងទ័ពនៅជាមួយគ្នាទាំងអស់ មិនទាន់ដកចេញជងកងទ័ពរដ្ឋាភិបាល នៅច្រើនដែរ ឲ្យខ្ញុំទៅរៀនជាប់ខ្សែគ្រូដដែល តាំងពីសមាហរណ៍កម្មមក ។

ដានីៈ ធ្វើគ្រូបានប៉ុន្មានឆ្នាំទៅ?

ហួនៈ ធ្វើគ្រូ មើលឆ្នាំ២០០៤-២០០៥ ខ្ញុំចូលនិវត្តន៍ ។

ដានីៈ លោកពូចាប់ផ្តើមធ្វើជាមេភូមិឆ្នាំណា?

ហួនៈ ខ្ញុំទើបតែធ្វើបាន១ឆ្នាំទេ ។

ដានីៈ ចុះមេភូមិមុន?

ហួនៈ មេភូមិមុនគាត់មានជំងឺ គាត់ស្លាប់ទៅ ។

ដានីៈ ទើបតែធ្វើបាន?

ហួនៈ បាន១ឆ្នាំ ថា១ឆ្នាំជាងចុះ ។

ដានីៈ កាលមុនធ្វើគ្រូទេ?

ហួនៈ ធ្វើគ្រូ ។

ដានីៈ កាលពីលោកពូមកបង្រៀននៅនេះ សៀវភៅអីនៅសេសសល់?

ហួនៈ សៀវភៅ ។

ដានីៈ សៀវភៅបង្រៀនកូនសិស្ស?

ហួនៈ ខ្ញុំឲ្យទៅគេ ឲ្យទៅខាងគ្រូថ្មី ។

ដានីៈ តែមុនសមាហរណកម្មក៏លោកពូធ្វើគ្រូ?

ហួនៈ មុនធ្វើគ្រូ ។

ដានីៈ តែសៀវភៅហ្នឹងទៅណាអស់?

ហួនៈ សៀវភៅដែលយើងចប់ហើយ សៀវភៅគ្មានទីដំរកស្រួលបួលត្រូវទឹកខូចអស់ គ្មានលាក់គ្មានលៀមទេ កូនសិស្សមួយៗម្នាក់ក៏ចែកចាយគ្នាបាត់អស់ទៅ មិនមាននៅទេ បើមានខ្ញុំលាក់ធ្វើអី បានសៀវភៅថ្មីមានទៅគិតគូរអាចាស់អីទៀត ។

ដានីៈ កាលហ្នឹងខាងតាប៉ុល ពត, ខាងតាម៉ុក ឈ្លោះគ្នាទៅ ខាងអន្លង់វែងថាខាងត្រពាំងប្រាសាទក្បត់ បើតាមយោបល់លោកពូម៉េច ក្បត់អីយ៉ាងម៉េច?

ហួនៈ ខាងនេះចោទខាងនោះ ខាងនោះចោទខាងនេះ ដើម្បីអ៊ីមួយខ្ញុំអត់ដឹង បើចោទអីចឹងឆាប់ចប់សង្គ្រាម បើគេមិនទុកចិត្តយើង មានតែយើងជាមួយរដ្ឋាភិបាលទៅ អីចឹងឆាប់ចប់ ប៉ុន្តែមិនដឹងជា មកពីមិនទុកចិត្តគ្នា មានផ្លូវមួយហ្នឹង អីចឹងបើគំនិតខ្ញុំវាមានចោទឈ្លោះគ្នាអីចឹងធ្វើឲ្យសភាពការណ៍ ទាំងខ្ញុំ ទាំងគេ ចូលរួបរួមជាមួយរដ្ឋាភិបាលហើយចប់សង្គ្រាម វាមើលឃើញទៅសុខសន្តិភាពហើយ ។

ដានីៈ លោកពូកាលដែលពូធ្លាប់បានឆ្លងកាត់តាំងពីសម័យសង្គ្រាម រហូតដល់សមាហរណកម្ម យើងចូលជាមួយរដ្ឋាភិបាល ចំពោះការរស់នៅ សេរីភាពខុសគ្នាម៉េចដែរ?

ហួនៈ មុនសមាហរណកម្ម?

ដានីៈ បាទ! មុនសមាហរណកម្ម ហើយក្រោយសមាហរណកម្ម ។

ហួនៈ និយាយរួមទៅរឿងសេរីភាពមុនសមាហរណកម្ម ជាសិទ្ធិសេរីភាពផ្នែករស់នៅ មិនសូវយល់ប៉ុន្មាន និយាយរួមខ្មែរក្រហមវាមានទឹកដីណាដើម្បីដើរតាមសេរីចង់ទៅណា មកណាមិនបានហើយផ្នែកនិយាយស្តីក៏គេមានការតាមដាន វាមិនសូវមានសេរីភាព ។ ក្រោយមកបានចូលរួបរួមជាមួយរដ្ឋាភិបាលតាំងសម័យសមាហរណកម្មមក គឺផ្នែករកស៊ីផ្ទាល់ខ្លួន ផ្នែកអ៊ីៗបានល្អហើយ អីចឹងខ្ញុំនិយាយដោយខ្លីអត់មានអីវែងឆ្ងាយ បានគុណរដ្ឋាភិបាលខ្ញុំទាំងអស់គ្នានេះមិនដឹងជាស្អីទេ មិនដឹងជារស់រាន្តមានដល់ថ្ងៃនេះ មានរដ្ឋាភិបាលជួយផ្តល់កំណើត និយាយរួមជួយផ្តល់កំណើត មានផ្ទះនៅ មានកង់ជិះ មានម៉ូតូ មានដំណាំដាំដុះ មានអីគ្រប់បែបយ៉ាង ។

ដានី៖ ទាក់ទងពីសេរីភាពខាងជំនឿ ខាងសាសនា ប្រពៃណីទំនៀមទំលាប់អីខុសគ្នាម៉េចដែរ? មុនសមាហរណកម្ម ហើយក្រោយសមាហរណកម្ម?

ហ្វូន៖ មុនសមាហរណកម្មផ្នែកសាសនាអី និយាយរួមមិនមែនកាន់ជើងទេ កាលដែលរត់ចូលព្រៃហើយ និយាយរួមខ្មែរក្រហមវាឈប់ប្រកាន់ហើយអ្នកណាជឿអីជឿទៅ តែគ្មានវត្តវ៉ាហើយចង់ធ្វើបុណ្យធ្វើទៅ ចង់រំលឹកធ្វើទៅ ចង់ឡើងផ្ទះ អ្នកណាមានផ្ទះធំក៏ឡើងទៅ តែគ្មានអ្នកណាមានផ្ទះធំទេ ចង់បានគ្នាសែនព្រេនម៉េចសែនទៅ វាដូចគ្នាទេ ។ ឯសព្វថ្ងៃមានវត្តវ៉ា អ្នកខ្លះក៏ចូលចិត្តធ្វើបុណ្យ ធ្វើទាន អ្នកខ្លះមិនចូលចិត្តធ្វើបុណ្យក៏អត់ទៅ ដូចគ្នា ។

ដានី៖ ទាក់ទងពីជំនឿសាសនាផ្សេងៗវិញ តើពីមុនហើយឥឡូវតើយើងអាចមានសេរីភាពទៅជឿសាសនាផ្សេងៗតាមចិត្តយើងចង់អីបានដែរ?

ហ្វូន៖ បាន តែនិយាយរួមបងប្អូននៅស្រុកនេះផ្នែកខាងគេជឿអីផ្សេងៗ ដូចមិនសូវជឿទេ ជឿលើព្រះពុទ្ធសាសនាព្រោះទំលាប់មកអីចឹងហើយ ជាសាសនាព្រាហ្ម ជាសាសនាយេស៊ូ គាត់មិនសូវជឿដែរ តែមានចំណែកខ្លះដែរ មានចូលដែរ ឃើញផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងការផ្ដល់ឲ្យប្រយោជន៍ដល់គេ ។

ដានី៖ ចូលដោយសារគេឲ្យប្រយោជន៍ទេ?

ហ្វូន៖ បាទ! គេឲ្យប្រយោជន៍ ។

ដានី៖ ដូចជាជួយឧបត្ថម្ភអីៗហ្នឹងសាសនាផ្សេងៗ ហ្នឹងសាសនាអី?

ហ្វូន៖ ដូចយេស៊ូ ឃើញចិញ្ចឹមក្មេង គេឲ្យយកស្អីៗ អ្នកខ្លះចូលជឿមែន តែភាគតិចណាស់ ។

ដានី៖ ការរាប់អាន ការរស់នៅស្និតស្នាលគ្នាវិញ រវាងអ្នកធ្លាប់រស់នៅជាមួយគ្នាកាលពីនៅលើភ្នំកាលពីមុនហ្នឹង ការរាប់អានគ្នា មនោសញ្ចេតនាយ៉ាងម៉េចដែរ? ហើយក្រោយមកពេលដែលយើងសមាហរណកម្មហើយ យើងរស់នៅផ្ទះរៀងៗខ្លួន ធ្វើស្រែ ធ្វើចំការ តាមដីរៀងៗខ្លួនហើយ តើវាយ៉ាងម៉េចដែរ? ខុសគ្នាយ៉ាងម៉េច?

ហ្វូន៖ ខាងផ្នែកសាមគ្គី រាប់អានគ្នាជាមិត្ត ជាភក្តិ ផ្សេងៗ គឺកន្លងមកជាមួយខ្មែរក្រហម មានពេលស្និតស្នាលជាមួយគ្នា រាប់អានគ្នាញឹកញាប់ តែមកដល់ឥឡូវរាប់អាននៅរាប់អានតែមិនសូវស្និតស្នាលទេ មួយៗខំជីវភាពរបស់ខ្លួន មិនសូវបានទៅដូចមុនទេ តែស្រឡាញ់គ្នាធម្មតាដូចមុនដែរ តែមិនសូវបានរាក់ទាក់ ដូចថាបែកគ្នាឆ្ងាយនឹកដែរ តែអត់បានទៅលេងទេ ព្រោះខំរវាចអត់ គេក៏ខំ យើងក៏ខំ ខំរៀងខ្លួន ។

ដានី៖ ទាក់ទងដូចថាកាលពីមុនជំនាន់សង្គ្រាម ញាតិមិត្តបងប្អូនយើងបានទាក់ទងគ្នា រាប់អានគ្នាជិតស្និតគ្នាដែលអត់? កាលពីសង្គ្រាមហើយហ្នឹងយើងសមាហរណកម្មហើយ វាមានលក្ខណៈ

ខុសគ្នាម៉េចដែរ ទាក់ទងនឹងការរាប់អាន ការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ញាតិមិត្តបងប្អូន ខុសគ្នាម៉េចដែរ?

ហួនៈ ដូចខ្ញុំនិយាយខាងដើម តែពេលឃើផ្កាត់បានទៅអើតគ្នាដែរ មិនដាច់ទេ នៅស្រឡាញ់ នៅរាប់អាន ដូចមិនសូវបានទៅញឹកញាប់ ។

ដានីៈ ដូចបងប្អូនបង្កើត កាលពីមុនយើងនៅសង្គ្រាម អ្នកនៅស្រុកកំណើតខុសគ្នាម៉េចដែរ?

ហួនៈ អត់អីទេ វាបានដឹងដំណឹងតាមទូរស័ព្ទខ្លះទៅ បានទៅលេងខ្លះទៅ បងប្អូនស្រឡាញ់ ជីវភាពបងប្អូនធម្មតា ។ ពីមុនខុសគ្នាត្រង់ចេះ កាលយើងនៅក្មេងបានរាក់ទាក់រាល់ថ្ងៃ ដល់មានកូនចៅដូចណាយដែរ ខំរៀងខ្លួនមិនថាបង្កើត មិនបង្កើតអីទេ យករៀងខ្លួន ។

ដានីៈ មានគ្រួសាររៀងៗខ្លួនហើយ?

ហួនៈ បាទ! គេចិញ្ចឹមកូន យើងចិញ្ចឹមកូន ។

ដានីៈ ចុះនៅក្នុងក្រុមគ្រួសារពូរាល់ថ្ងៃ យ៉ាងម៉េចដែរយើងល្អកល្អើនជាមួយគ្នាដែរ? កូនប្រពន្ធ?

ហួនៈ ខ្ញុំអត់មានអីទេ តាំងពីចាប់ដៃគ្នាមក និយាយរួមគឺមិនដែលចេះជេរគ្នា មិនដែលចេះមាត់ធំមាត់តូច មានខ្លះរឿងជេរប្តី ប្រពន្ធ ប្រមាថកាតទានហែកកេរ្តិ៍មិនដែរ ។

ដានីៈ ហើយកូនចៅអី?

ហួនៈ កូនចៅខ្ញុំដូចគ្នា ។

ដានីៈ ពេលទំនេរ ពេលដែលជួបជុំគ្នា ប្តីប្រពន្ធកូនចៅ ពេលយើងជួបជុំគ្នា ច្រើនតែពិភាក្សារឿងអីទៅ? ជួបជុំគ្នា?

ហួនៈ រកស៊ី មានបាន ជួយណែនាំកូនផ្នែកខាងរកស៊ីខំទៅ ផ្នែកខាងនិយាយស្តីសីលធម៌កុំឲ្យវាសមស្របប្រជាពលរដ្ឋល្អ រកស៊ីមិនដែលឲ្យកូនមានគំនិត ដូចអ្នករកស៊ីឈើសព្វថ្ងៃឲ្យកូនទៅ អត់ទេមិនចង់ឲ្យទៅទេ មិនឲ្យទៅ ។

ដានីៈ ឈើក្រញូងហ្នឹង?

ហួនៈ បាទ!

ដានីៈ គេចូលទៅកាប់ឈើ ។

ហួនៈ បាទ!

ដានីៈ អត់ចង់ឲ្យកូនទៅ អត់ឲ្យទៅ?

ហួនៈ អត់ឲ្យទៅ ។

ដានីៈ ចុះឥឡូវវិញនៅស្រុកភូមិលោកពូ សេរីភាពខាងប្រកាន់ ខាងបក្សនយោបាយយ៉ាងម៉េចដែរ យើងមានសេរីភាពអីគ្រប់គ្រាន់ដែរ?

ហួនៈ ខាងនយោបាយ គណបក្សនិយាយរួមអ្នកចាស់គាំទ្រខាងរដ្ឋាភិបាលយើង ព្រោះរដ្ឋាភិបាលយើងបានផ្ដល់ជីវិត មិនសូវជាមានខាងផ្សេងៗនេះដែរ ។

ដានីៈ ខាងគណបក្សប្រឆាំងអត់សូវមានទេ?

ហួនៈ មិនសូវមានទេ ។

ដានីៈ មានគេកាន់ដែរ?

ហួនៈ មានខ្លះ មានលួចគូសសន្លឹកឆ្នោតមានខ្លះ មិនអត់ទេ តែភាគច្រើនគឺ ។

ដានីៈ ដោយសារលោកពូកាលពីមុនធ្លាប់ជាអតីតលោកគ្រូធ្លាប់បង្រៀន បើតាមយោបល់របស់លោកពូ ពូគិតថាតើកូនសិស្សដែលរៀនសព្វថ្ងៃនេះគួរតែមានបង្រៀនមុខវិជ្ជាទាក់ទងពីប្រវត្តិសាស្ត្រ ជាពិសេសដូចជាអ្វីដែលខ្ញុំបានជំរាបលោកពូព្រឹកមិញ ពីព្រោះពួកខ្ញុំមានគម្រោងខាងចងក្រង ស្រាវជ្រាវសរសេរប្រវត្តិសាស្ត្រអន្លង់វែង-ត្រពាំងប្រាសាទហ្នឹង បើតាមយោបល់លោកពូវិញគួរតែបញ្ចូលប្រវត្តិសាស្ត្រ ដើម្បីបង្រៀនទៅដល់ក្មេងៗ ដើម្បីយល់ដឹងប្រវត្តិយើង ជាពិសេសនៅតំបន់អន្លង់វែង ត្រពាំងប្រាសាទ ។ តើថាកាលពីមុនកាលពីសម័យតស៊ូ សមាហរណកម្មហើយ យ៉ាងម៉េចៗគួរតែឲ្យក្មេងយល់ដឹងពីបញ្ហាហ្នឹងដែរតាមយោបល់?

ហួនៈ តាមយោបល់ខ្ញុំ ការតស៊ូពីប្រវត្តិសាស្ត្រ បើថាស្រេចលើខ្ញុំក៏មិនមែន បើខ្ញុំថាដាក់បញ្ចូលទៅបើខាងដឹកនាំ ថ្នាក់លើថាមិន ។

ដានីៈ អត់ទេ ខ្ញុំចង់ដឹងយោបល់លោកពូ?

ហួនៈ គំនិតខ្ញុំស្រេចទៅលើថ្នាក់ដឹកនាំទេ ខ្ញុំថាចង់ក៏មិនទំនង ។

ដានីៈ ចង់ដឹងពីចិត្តលោកពូគិតថាម៉េច?

ហួនៈ ខ្ញុំមិនសូវហ៊ានថា បើខ្ញុំថាទៅ អ្នកដឹកនាំអាមួយនេះម៉េចចេះ ។

ដានីៈ បាទ! ខ្ញុំដូចជាអស់សំនួរត្រូវសួរនាំលោកពូទៀតហើយ អ៊ីចឹងលោកពូមានអីចង់បញ្ជាក់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំ ។

ហួនៈ ខ្ញុំអត់ទេ ខ្ញុំសំណូមពរថារឿងសួរខ្ញុំមិញ ចង់ដាក់បញ្ចូលទៅក្នុងកម្មវិធី ឬអ្វីមួយដើម្បីក្មេងជំនាន់ក្រោយ ហ្នឹងស្រេចលើអ្នកដឹកនាំ ខ្ញុំសំណូមពរតែប៉ុណ្ណឹងទេ ឯខ្ញុំតាមបាន តាមសំណូមពរ ឬតាមអ្នកដឹកនាំវិញ បើគួរតែបញ្ចូលបានក៏បញ្ចូលទៅ ដើម្បីលើកកកាយខ្ញុំអត់ចង់មានអីទេ ។

ដានីៈ អ៊ីចឹងខ្ញុំអរគុណលោកពូច្រើនដែលផ្ដល់បទសម្ភាសន៍ជាមួយខ្ញុំនេះ អរគុណលោកពូច្រើន ។

**ចប់**